


# វិញ្ញាសាតែងសេចក្ដី
# ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

បង្រៀនដោយ **វ៉ាន់ វី**
សាស្ត្រាចារ្យជំនួយនៃដេប៉ាតឺម៉ង់ភាសាវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## វិញ្ញាសាទី៣

**ប្រធានៈ** គេលើកឡើងថា «នៅក្នុងសង្គមខ្មែរ ស្ត្រីគឺជាដៃគូរបស់បុរសក្នុងការកំណត់ភាពគង់វង្ស និងវឌ្ឍនភាពរបស់សង្គមជាតិ» ។ ចូរស្រាយបំភ្លឺ ដោយលើកឧទាហរណ៍ពីសង្គម ប្រវត្តិសាស្ត្រ និងអក្សរសិល្ប៍មកបង្ហាញ ។

# គម្រោងតែងសង្ខេប

## ១- សេចក្តីផ្តើម

**ក- លំនាំបញ្ហា៖** និយាយទូទៅពីការចូលរួមរបស់ស្ត្រីក្នុងសង្គមខ្មែរ ។

**ខ- ចំណូលបញ្ហា៖** អាស្រ័យហេតុនេះហើយ ទើបមានមតិលើកឡើងថា «នៅក្នុងសង្គមខ្មែរ ស្ត្រីគឺជាដៃគូរបស់បុរសក្នុងការកំណត់ភាពគង់វង្ស និងវឌ្ឍនភាពរបស់សង្គមជាតិ» ។

**គ- ចំណោទបញ្ហា៖** តើទស្សនៈខាងលើនេះមានខ្លឹមសារយ៉ាងដូចម្តេច ?

## ២- តួសេចក្តី

**ក- ឃ្លាភ្ជាប់សេចក្តី៖** មុននឹងបកស្រាយមតិរបស់ប្រធានខាងលើ យើងគួរយល់ន័យនៃពាក្យគន្លឹះខ្លះជាមុនសិន ។

**ខ- ពន្យល់ពាក្យគន្លឹះ៖**

- **ស្ត្រី៖** នារី មនុស្សស្រីជាទូទៅ
- **ភាពគង់វង្ស៖** ភាពស្ថិតស្ថេរ ចីរកាល មិនបាត់បង់
- **វឌ្ឍនភាព៖** ភាពរីកចម្រើន ឬដំណើរនាំឱ្យរុងរឿង ។

**គ- ពន្យល់ន័យប្រធាន៖** ដូច្នេះ ទស្សនៈប្រធានខាងលើមានន័យថា នៅក្នុងសង្គមខ្មែរ មនុស្សស្រីជាដៃគូរបស់បុរស ដែលជួយឱ្យសង្គមជាតិអាចស្ថិតស្ថេរចីរកាល មិនបាត់បង់ និងនាំឱ្យរីកចម្រើនរុងរឿង ។

**ឃ- បកស្រាយប្រធាន៖**

**ឃ.១- គំនិតសំខាន់ទី១៖** ស្ត្រីជួយឱ្យសង្គមខ្មែរគង់វង្សស្ថិតស្ថេរ មានលំនឹងតាមរយៈការថែទាំ និងការការពារទាំងក្រុមគ្រួសារ និងសង្គមជាតិ ។

ឧទាហរណ៍៖ ព្រះនាងលីវយី, កម្លាំងជីវពលនារីក្លាហាន, នាងនី នាងប៊ី ។

**ឃ.២- គំនិតសំខាន់ទី២៖** ស្ត្រីជួយកសាងសង្គមឱ្យរីកចម្រើន។

ឧទាហរណ៍៖ ប្រពន្ធគ្រប់លក្ខណ៍ក្នុងរឿងមាយើង, ព្រះនាងឥន្ទ្រទេវី, សម្ដេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសមៈនារីរ័ត្នសិរីវឌ្ឍនា, ស្ត្រីជាមេឃុំចៅ-សង្កាត់...។

**ង- សរុប ៖** សរុបមក ភាពស្ថិតស្ថេរ និងភាពរីកចម្រើនរបស់សង្គមពិតជាកើតពីការចូលរួមនិងការបញ្ចេញអស់កម្លាំងកាយចិត្ត កម្លាំងប្រាជ្ញាស្មារតីរបស់ស្ត្រីនៅគ្រប់កាលៈទេសៈ ។

**៣- សេចក្ដីបញ្ចប់**

**ក- វាយតម្លៃប្រធាន៖** ពំនោលរបស់ប្រធានពិតជាមានខ្លឹមសារល្អសម្រាប់អប់រំមនុស្សទាំងឡាយឱ្យឃើញពីគុណសម្បត្តិរបស់ស្ត្រី ដែលបានចូលរួមការពារនិងកសាងសង្គមជាតិ ។

**ខ- យោបល់ផ្ទាល់ខ្លួន៖** ក្នុងនាមយើងជាពលរដ្ឋខ្មែរ យើងត្រូវនាំគ្នាលើកតម្កើងតម្លៃរបស់ស្ត្រីទាំងអស់គ្នា ។

## សេចក្ដីអធិប្បាយ

តាំងពីអតីតកាលរហូតដល់បច្ចុប្បន្ន សង្គមខ្មែរនៅគង់វង្សនិងរីកចម្រើនក៏ដោយសារតែមានការចូលរួមពីសំណាក់អ្នកដឹកនាំនិងប្រជាពលរដ្ឋគ្រប់ស្រទាប់ ។ ក្នុងនោះ ស្ត្រីគឺជាដៃគូដ៏សំខាន់របស់បុរស ដែលជាកម្លាំងចលករក្នុងការការពារ និងកសាងសង្គមជាតិដោយពុំអាចខ្វះបាន ។ អាស្រ័យហេតុនេះហើយ ទើបមានមតិលើកឡើងថា « នៅក្នុងសង្គមខ្មែរ ស្ត្រីគឺជាដៃគូរបស់បុរសក្នុងការកំណត់ភាពគង់វង្ស និងវឌ្ឍនភាពរបស់សង្គមជាតិ » ។

តើទស្សនៈខាងលើនេះមានខ្លឹមសារយ៉ាងដូចម្ដេច ?

មុននឹងបកស្រាយមតិរបស់ប្រធានខាងលើ យើងគួរយល់ន័យនៃពាក្យគន្លឹះខ្លះជាមុនសិន ។ ពាក្យ « ស្ត្រី » សំដៅយកនារីឬមនុស្សស្រីជាទូទៅ។ ឯពាក្យ « ភាពគង់វង្ស » បានសេចក្តីថា ភាពស្ថិតស្ថេរ ចីរកាល មិនបាត់បង់ ។រីឯពាក្យ « វឌ្ឍនភាព » មានន័យថា ភាពរីកចម្រើន ឬដំណើរនាំឱ្យរុងរឿង ។ ដូចនេះ ទស្សនៈប្រធានចង់បានន័យថា នៅក្នុងសង្គមខ្មែរ មនុស្សស្រីជាដៃគូរបស់បុរស ដែលជួយឱ្យសង្គមជាតិអាចស្ថិតស្ថេរ ចីរកាល មិនបាត់បង់ និងនាំឱ្យរីកចម្រើនរុងរឿង ។

ពិតមែនហើយ នៅក្នុងសង្គមខ្មែរយើង ស្ត្រីពិតជាដៃគូរបស់បុរសដែលមិនអាចខ្វះបាន ក្នុងការរក្សាភាពគង់វង្ស និងភាពរីកចម្រើនរបស់សង្គម ក៏ព្រោះតែស្ត្រីបានចូលរួមការពារ ព្រមទាំងកសាងសង្គមខ្មែរយ៉ាងមុះមុតនៅគ្រប់សម័យកាល ។ ស្ត្រីខ្មែរបានចូលរួមរក្សាឱ្យសង្គមស្ថិតស្ថេរ មានលំនឹង ដោយមិនត្រឹមតែបានជួយមើលថែទាំគ្រួសារប៉ុណ្ណោះទេ ថែមទាំងបានជួយរក្សាការពារប្រទេសជាតិទៀតផង ។ ជាក់ស្តែង នៅក្នុងដើមដំបូងនៃប្រវត្តិសាស្ត្រខ្មែរ គេឃើញមានព្រះនាងលីវយី ជាក្សត្រីខ្មែរដំបូងបង្អស់ បានប្រយុទ្ធតស៊ូនឹងព្រះបាទហ៊ុនទៀនដែលយាងមកពីទីឆ្ងាយ ។ ទោះជាត្រូវបរាជ័យ ហើយត្រូវរៀបអភិសេកនឹងព្រះអង្គក៏ដោយ ក៏ព្រះនាងបានខិតខំការពារទឹកដីរបស់ព្រះនាងដែរ ។ មកដល់ចុងសម័យបារាំង យើងឃើញមាននារីខ្មែរជាច្រើននាក់បានចូលរួមជាកម្លាំងជីវពលនារីក្លាហាន ដែលដឹកនាំដោយសម្តេចព្រះ នរោត្តមសីហនុ ដើម្បីទាមទារឯករាជ្យពីអាណានិគមបារាំង ។ បើក្រឡេកមើលមកស្នាដៃអក្សរសិល្ប៍វិញ យើងក៏ឃើញអ្នកនិពន្ធបានរំលេចពីវីរភាពរបស់នារីខ្មែរដែរ ។ ជាតួយ៉ាង ក្នុងរឿងភូមិតិរច្ឆាន នាងនីនិងនាងប៊ីបានចេញមុខការពារជាតិខ្មែរយ៉ាងខ្លាំងក្លាប្រឆាំងនឹងការជិះជាន់របស់បារាំងនៅភូមិក្រាំងលាវ ខេត្តកំពង់ឆ្នាំង ។ ចំណែកជំទាវស្រែន្យក្នុងរឿងតេជោយ៉ត ក៏បានជួយតេជោមាសជាប្តីឱ្យកម្ចាត់ជនបះបោរ គឺស្តេចសំរ៉ែ ដោយប្រើប្រាជ្ញា ធ្វើឱ្យសង្គមមានសន្តិសុខល្អឡើងវិញ ។

លើសពីនេះទៅទៀត ភាពរីកចម្រើនរបស់សង្គមតែងតែកើតពីការចូលរួមកសាងរបស់ស្ត្រីតាមរយៈសកម្មភាពផ្សេងៗ មានដូចជាដឹកនាំគ្រួសារឱ្យមានជីវភាពធូរធារ និងមានកិត្តិយសខ្ពង់ខ្ពស់ ។ ដូចមានរឿងមាយើងជាឧទាហរណ៍ស្រាប់ ។ នាងគ្រប់លក្ខណ៍ប្រពន្ធទីពីររបស់មាណពបាននាំឱ្យមាណពជាប្តីបានចេះដឹង ចេះរកស៊ីជួញដូរ និងបានបង្ហាត់ប្តីរហូតក្លាយជាមន្ត្រីធំ ដោយបានជួយជីវិតព្រះរាជាជាច្រើនលើក ។ បន្ថែមពីលើនេះ ស្ត្រីក៏ជាគ្រូបង្រៀន ជាអ្នកកសាងវប្បធម៌ជាតិយ៉ាងល្បីល្បាញដែរ ។ តាមរយៈប្រវត្តិសាស្ត្រខ្មែរនាសម័យអង្គរ យើងឃើញមានព្រះនាងឥន្ទ្រទេវី ជាអគ្គមហេសីនៃព្រះបាទជ័យវរ្ម័នទី៧ បានជួយជ្រោមជ្រែងឱ្យវិស័យអប់រំ និងវប្បធម៌ខ្មែររុងរឿង ។ ព្រះនាងជាកវីនិពន្ធ ជាសាស្ត្រាចារ្យ និងជាសាកលវិទ្យាធិការិនីដ៏ឆ្នើមនៅសម័យនោះ ដែលបានបញ្ចេញអស់កម្លាំងកាយចិត្ត ចូលរួមសាងប្រទេសឱ្យល្បីរន្ទឺ ។ លុះក្រោយមកទៀត ក្នុងសម័យសង្គមរាស្ត្រនិយម សម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ កុសមៈនារីរ័ត្នសិរីវឌ្ឍនា ទ្រង់បានដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការអប់រំសិទ្ធិស្ត្រី និងបានលើកតម្លៃសិល្បៈ វប្បធម៌ជាតិឱ្យប្រសើរខ្ពង់ខ្ពស់ ។ ជាពិសេស ទ្រង់បានផ្តួចផ្តើមគំនិតបង្កើតរបាំអប្សរានៅឆ្នាំ១៩៦១ ហើយរបាំនេះត្រូវបានអង្គការយូណេស្កូចុះក្នុងបញ្ជីបេតិកភណ្ឌអរូបីនៃមនុស្សជាតិនៅឆ្នាំ២០០៣ ។

មិនត្រឹមតែប៉ុណ្ណោះ ស្ត្រីក៏ជាអ្នកដឹកនាំអភិវឌ្ឍមូលដ្ឋាននៅថ្នាក់ក្រោមជាតិដែរ ។ ជាក់ស្តែង ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ (២០២២-២០២៧) មានស្ត្រី ១៧៣ នាក់ (ស្មើនឹង ១១ ភាគរយ) បានជាប់ជាមេឃុំ-ចៅសង្កាត់ ។ អត្រានេះបានកើនឡើងលើសអាណត្តិមុនៗ ហេតុនេះស្ត្រីក៏នឹងបានចូលរួមដោះបញ្ហាប្រឈមនៅមូលដ្ឋានបានច្រើនជាងមុនដែរ ។ បើងាកមកមើល អក្សរសិល្ប៍វិញ យើងក៏ឃើញអ្នកនិពន្ធបានលើកឡើងពីការចូលរួមរបស់ស្ត្រីនៅតាមភូមិឃុំដែរ មានជាអាទិ៍អ្នកស្រីបូរ ។ ក្រោមការដឹកនាំរបស់អ្នកស្រីបូរ ភូមិខ្សាច់ពោយបាន

កែប្រែមុខមាត់ និងមានការអភិវឌ្ឍគួរជាទីមោទនៈ គឺប្រជាជនពីដើមមិនចេះអក្សរ បានចេះដឹងយល់សព្វបែបយ៉ាង ផ្លូវថ្នល់ពីដើមក្រហេងក្រហូង ឥឡូវប្រែជាស្អាត ។

សរុបមក ភាពស្ថិតស្ថេរ គង់វង្ស និងភាពរីកចម្រើនរបស់សង្គមពិតជាកើតចេញពីការចូលរួមនិងការបញ្ចេញអស់កម្លាំងកាយចិត្ត កម្លាំងប្រាជ្ញាស្មារតីរបស់ស្ត្រីនៅគ្រប់កាលៈទេសៈ ។

តាមការបកស្រាយខាងលើឃើញថា ពំនោលរបស់ប្រធានពិតជាមានខ្លឹមសារល្អសម្រាប់អប់រំមនុស្សទាំងឡាយឱ្យឃើញពីគុណសម្បត្តិរបស់ស្ត្រី ដែលបានចូលរួមការពារនិងកសាងសង្គមជាតិយើង ។ ក្នុងនាមយើងជាពលរដ្ឋខ្មែរ យើងត្រូវនាំគ្នាលើកតម្កើងតម្លៃរបស់ស្ត្រីទាំងអស់គ្នា ហើយត្រូវចៀសវាងការប្រើអំពើហិង្សាឬប្រមាថទៅលើស្ត្រី ព្រោះក្នុងសង្គមខ្មែរស្ត្រីជាអ្នកមានគុណ និងជាដៃគូដ៏ចាំបាច់មិនអាចខ្វះបានរបស់បុរសក្នុងការធ្វើឱ្យសង្គមគង់វង្ស និងរីកចម្រើនទៅមុខ ។

# ឯកសារពិគ្រោះ


កាន់ ចាន់ដារ៉ា និង វ៉ាន់ វី ***តែងសេចក្ដី៖ ប្រធានពន្យល់*** ភ្នំពេញ ឆ្នាំ២០១២។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្ដី*** *(សម្រាប់មធ្យមសិក្សាទុតិយភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៧។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ***វិធីសាស្ត្រនៃការសរសេរតែងសេចក្ដី*** *(សម្រាប់មធ្យមសិក្សាបឋមភូមិ)* ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨។

សែម សូរ, ថោង ផែល និងអ្នកដទៃទៀត ***វិញ្ញាសាតែងសេចក្ដីគំរូ*** បណ្ណាគារមាយើង ឆ្នាំ១៩៧១។